**ការអធិស្ឋាន និងការបំផុសគំនិត**

ប្រធាន ប៊ិយដ៏ យេ ផាកកឺ
ប្រធាននៃក្រុមពួកសាវកដប់ពីរនាក់

*បទពិសោធន៍នៃការបំផុសគំនិត និងការអធិស្ឋានទាំងនេះ ពុំមែនជារឿងចម្លែកនៅក្នុងសាសនាចក្រនោះឡើយ ។ ការណ៍ទាំងនេះគឺជាផ្នែកមួយនៃវិវរណៈ ដែលព្រះវរបិតាសួគ៌យើងបានប្រទានដល់យើង ។*

ព្រះវរបិតាមិនបានបញ្ជូនកូនចៅរបស់ទ្រង់ឱ្យទៅកាន់ដែនដីមួយដ៏សែនឆ្ងាយ ហើយប្រកបដោយគ្រោះថ្នាក់ និងជាទីកន្លែងដែល លូស៊ីហ្វើរ មានសិទ្ធិធ្វើអ្វីតាមចិត្ត ដើម្បីទទួលយកការសាកល្បងពីជីវិត ដោយគ្មានប្រទានអំណាចការពារខ្លួនតាំងពីដំបូងនោះឡើយ ។ ទ្រង់ក៏បានប្រទានដល់ពួកគេនូវមធ្យោបាយទំនាក់ទំនង ដើម្បីឱ្យពួកគេអាចទំនាក់ទំនងនឹងទ្រង់ក្នុងនាមជាបុត្រា និងបិតាផងដែរ ។ កូនចៅគ្រប់រូបរបស់ព្រះវរបិតាយើងដែលបានបញ្ជូនមកកាន់ផែនដីនេះ គឺត្រូវបានប្រទានឱ្យនូវព្រះវិញ្ញាណនៃព្រះគ្រីស្ទ ឬជាពន្លឺនៃព្រះគ្រីស្ទ ។ 1 គ្មានយើងណាម្នាក់ត្រូវបានទុកចោលនៅទីនេះតែម្នាក់ឯងដោយគ្មានសង្ឃឹម និងទទួលបានការដឹកនាំ និងការប្រោសលោះនោះឡើយ ។

ការស្តារឡើងវិញបានចាប់ផ្តើមឡើងជាមួយនឹងការអធិស្ឋានរបស់ក្មេងប្រុសម្នាក់ ដែលមានអាយុ 14 ឆ្នាំ និងការនិមិត្តមួយស្តីអំពីព្រះវរបិតា និងព្រះរាជបុត្រា ។ ហើយគ្រាកាន់កាប់ត្រួតត្រានៃពេលពេញកំណត់មួយ ក៏បានចាប់ផ្តើមឡើង ។

ការស្តារឡើងវិញនៃដំណឹងល្អបាននាំមកនូវចំណេះដឹងអំពីជីវិតមុនឆាកជីវិតនេះ ។ ចេញពីព្រះគម្ពីរយើងបានដឹងពីការប្រឹក្សានៅស្ថានសួគ៌ និងការសំរេចចិត្តដើម្បីបញ្ជូនបុត្រាបុត្រីនៃព្រះ មកកាន់ជីវិតរមែងស្លាប់ ដើម្បីទទួលរូបកាយ និងទទួលការសាកល្បង ។ យើងជាកូនចៅរបស់ព្រះ នៅក្នុងជីវិតលើផែនដីនេះ យើងមានរូបកាយជាវិញ្ញាណដែលគ្របបាំងដោយរូបកាយជាសាច់ ។ ព្រះគម្ពីរបានចែងថា "តើអ្នករាល់គ្នាមិនដឹងទេឬអី ថាខ្លួនអ្នករាល់គ្នាជាព្រះវិហារនៃព្រះ ហើយថាព្រះវិញ្ញាណនៃព្រះ ទ្រង់សណ្ឋិតក្នុងអ្នករាល់គ្នា?" ( កូរិនថូសទី 1 3:16) ។

ក្នុងនាមជាកូនចៅនៃព្រះ នោះយើងបានរៀនសូត្រថា យើងគឺជាផ្នែកមួយនៃ"ផែនការនៃសុភមង្គលដ៏មហិមា"របស់ទ្រង់ ( អាលម៉ា 42:8) ។

យើងបានដឹងថា កើតមានសង្គ្រាមមួយនៅស្ថានសួគ៌ ហើយលូស៊ីហ្វើរ និងពួកអ្នកដែលតាមវាត្រូវបានបណ្តេញចេញ ដោយមិនឱ្យមានរូបកាយ :

"សាតាំងដែលជាសត្វពស់ពីចាស់បុរាណ គឺជាអារក្សដែលបានបះបោរទាស់នឹងព្រះ ហើយខំស្វែងរក ដើម្បីយកនគរនៃព្រះរបស់យើង និងព្រះគ្រីស្ទនៃទ្រង់---

"ហេតុដូច្នោះហើយ វាបានធ្វើសង្គ្រាមជាមួយនឹងពួកបរិសុទ្ធនៃព្រះ ហើយព័ទ្ធជុំវិញពួកគេ" ( គ. និង ស. 76:28--29) ។

យើងត្រូវបានប្រទានឱ្យនូវសិទ្ធិជ្រើសរើស។ 3 យើងត្រូវប្រើវាដោយឈ្លាសវៃ ហើយបន្តនៅជិតនឹងព្រះវិញ្ញាណ ៖ បើមិនដូច្នោះទេ យើងនឹងឃើញថា ខ្លួនឯងកំពុងងាកទៅរកការអូសទាញរបស់មារសត្រូវទាំងល្ងង់ខ្លៅជាពុំខានឡើយ។ យើងដឹងថា តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ នោះកំហុសរបស់យើងអាចនឹងជំរះឱ្យស្អាតបាន ហើយថារូបកាយនៃជីវិតរមែងស្លាប់របស់យើងនឹងត្រូវបានស្ដារឡើងវិញទៅជារូបកាយដ៏ល្អឥតខ្ចោះ។

"ត្បិតមើលចុះ ព្រះវិញ្ញាណនៃព្រះគ្រីស្ទត្រូវបានប្រទានដល់មនុស្សគ្រប់រូប ដើម្បីឱ្យគេអាចដឹងខុស និងត្រូវ ហេតុដូច្នោះ ហើយខ្ញុំបង្ហាញដល់អ្នកនូវវិធីវិនិច្ឆ័យ ត្បិតគ្រប់ទាំងអ្វីៗដែលអញ្ជើញឱ្យធ្វើល្អ ហើយដែលបញ្ចុះបញ្ចូលឱ្យជឿដល់ព្រះគ្រីស្ទ នោះគឺបានចាត់មកពីព្រះចេស្ដា និងអំណោយទាននៃព្រះគ្រីស្ទ ហេតុដូច្នោះហើយ អ្នករាល់គ្នាអាចដឹងដោយ ដ៏រឹងដ៏ឥតខ្ចោះថា មកពីព្រះ" (មរ៉ូណៃ 7:16)។

មានទំនាក់ទំនងដ៏ល្អឥតខ្ចោះមួយតាមរយៈព្រះវិញ្ញាណ "ត្បិតព្រះវិញ្ញាណនៃទ្រង់ស្ទង់មើលគ្រប់ការទាំងអស់ ព្រមទាំងសេចក្ដីជ្រាលជ្រៅនៃព្រះដែរ" (កូរិនថូសទី 1 2:10)។

បន្ទាប់ពីបានជ្រមុជទឹកចូលក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ នោះពិធីបរិសុទ្ធទីពីរនឹងកើតមានឡើង គឺ ៖ "ការដាក់ដៃលើក្បាលសំរាប់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ" (មាត្រានៃសេចក្ដីជំនឿ 1:4)។

សម្លេងនៃការបំផុសគំនិតដ៏ផ្អែមល្ហែម ហើយស្ងៀមស្ងាត់នោះ ភាគច្រើនកើតមានឡើងជាអារម្មណ៍ ជាជាងការបញ្ចេញជាសម្លេង។ ក៏អាចកើតមានជាប្រាជ្ញាដ៏បរិសុទ្ធនៅក្នុងគំនិតផងដែរ។ ព្រះវិញ្ញាណបរិសុទ្ធទំនាក់ទំនងជាមួយនឹងវិញ្ញាណ របស់យើងតាមរយៈគំនិតជាជាងតាមកាយវិញ្ញាណ។ 4 ការដឹកនាំនេះកើតមានឡើងជាគំនិត ជាអារម្មណ៍ តាមរយៈ ការបំផុសគំនិត និងអារម្មណ៍រំភើប។ 5 យើងអាចនឹង *ទទួលអារម្មណ៍* ពីពាក្យសម្ដីនៃការប្រាស្រ័យទាក់ទងខាងវិញ្ញាណ ជាជាង *ការស្ដាប់ឮ* ពាក្យទាំងនោះ ហើយអាច *មើលឃើញ* ដោយភ្នែកខាងវិញ្ញាណជាជាងភ្នែកខាងសាច់ឈាម។6

ខ្ញុំបានបំរើនៅក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ជាមួយនឹងអែលឌើរ ឡឺហ្គ្រង់ រីឆាដ អស់រយៈពេលជាច្រើនឆ្នាំ។ គាត់បានទទួលមរណភាពនៅក្នុងវ័យ 96 ឆ្នាំ។ គាត់បានប្រាប់យើងថា កាលពីមានអាយុ 12 ឆ្នាំ គាត់បានចូលរួមនៅក្នុងសន្និសីទទូទៅដ៏អស្ចារ្យមួយនៅក្នុងរោងឧបោសថ។ នៅក្នុងសន្និសីទនោះ គាត់បានស្ដាប់ប្រសាសន៍របស់ប្រធាន វិលហ្វូឌ វូឌ្រុព្វ។

ប្រធាន វូឌ្រុព្វ បានលើកឡើងពីបទពិសោធន៍មួយនៃការបំផុសគំនិតដោយព្រះវិញ្ញាណ។ គណៈប្រធានទីមួយ បានបញ្ជូនលោកឱ្យ "ប្រមូលផ្ដុំពួកបរិសុទ្ធនៃព្រះទាំងអស់នៅតំបន់ញូវអ៊ីងឡែន និងប្រទេសកាណាដា ហើយបង្កើតទីក្រុងស៊ីយ៉ូននៅក្នុងចំណោមពួកគេ" ។7

លោកបានឈប់សំរាកនៅឯផ្ទះរបស់បងប្រុសម្នាក់ក្នុងរដ្ឋអ៊ិនឌីអាណា ហើយក៏បានដាក់រទេះរបស់លោកនៅក្បែរបរិវេណផ្ទះ ជាកន្លែងដែលលោក និងភរិយា ព្រមទាំងកូនរបស់លោកម្នាក់បានសំរាកនៅទីនោះ ខណៈដែលសមាជិកគ្រួសារផ្សេងទៀតសំរាក

នៅខាងក្នុងផ្ទះ។ នៅយប់នោះ បន្ទាប់ពីលោកចូលទៅសំរាកមិនបានយូរប៉ុន្មានផង ព្រះវិញ្ញាណក៏បានខ្សឹបប្រាប់ ដោយព្រមាន លោកថា "ក្រោកឡើង ហើយអូសរទេះរបស់ឯងចេញទៅ"។ លោកបានក្រោកឡើង ហើយបានអូសរទេះរបស់ខ្លួនទៅដាក់ឱ្យឆ្ងាយពីកន្លែងដើម។ នៅពេលលោកបានត្រឡប់ទៅសំរាកវិញ នោះព្រះវិញ្ញាណបានមានបន្ទូលប្រាប់លោកម្តងទៀតថា : "ចូរទៅអូសសេះរបស់ឯង ចេញឱ្យឆ្ងាយពីដើមឈើនោះ"។ លោកបានធ្វើតាម រួចហើយក៏បានចូលទៅសំរាកវិញទៅ។

ក្រោយមក ត្រឹមតែ 30 នាទីប៉ុណ្ណោះ មានខ្យល់កួចមួយបានកួចបំបាក់ដើមឈើដែលលោកបានយកសេះទៅចងនោះ បាក់ធ្លាក់មកលើដី។ ខ្យល់កួចនោះបានបក់បោកនៅលើផ្ទៃដីប្រមាណ 90 ម៉ែត្រ នៅចន្លោះរបងទាំងសង្ខាង។ មានដើមឈើដែលមានទំហំមួយម៉ែត្រកន្លះច្រើនរាប់មិនអស់ បានបាក់ធ្លាក់នៅត្រង់កន្លែងដែលលោកបានដាក់រទេះសេះនោះ។ ដោយស្តាប់តាមការបំផុសគំនិតពីព្រះវិញ្ញាណអែលឌើរ វូឌ្រុព្វ បានជួយសង្គ្រោះដល់ជីវិតខ្លួនឯង និង ជីវិតរបស់ភរិយា ព្រមទាំងកូនរបស់លោកផងដែរ។8

ព្រះវិញ្ញាណដូចគ្នានេះ ក៏អាចបំផុសគំនិតដល់អ្នករាល់គ្នា និងជួយការពារដល់អ្នកផងដែរ។

នៅពេលខ្ញុំត្រូវបានហៅឱ្យធ្វើជាពួកអ្នកមានសិទ្ធិអំណាចទូទៅជាលើកទីមួយ កាលពីជិត 50 ឆ្នាំមុន នោះយើងបានរស់នៅក្នុងផ្ទះដ៏តូចមួយនៅជ្រលងភ្នំយូថាហ៍ ដែលយើងបានហៅថាជាកសិដ្ឋានរបស់យើង។ យើងមានសត្វគោ សេះ មាន់ ហើយមានកូនច្រើន។

នៅថ្ងៃសៅរ៍មួយ ខ្ញុំបានបើករថយន្តទៅអាកាសយានដ្ឋាន ដើម្បីជិះយន្តហោះទៅចូលរួមសន្និសីទស្តេកមួយនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា។ ប៉ុន្តែ សត្វគោរបស់ខ្ញុំដែលជិតនឹងកើតកូនកំពុងជួបបញ្ហា។ កូនគោនោះបានកើតរួច ប៉ុន្តែមេរបស់វាមិន អាចក្រោកឈរបានឡើយ។ យើងបានទូរស័ព្ទហៅពេទ្យសត្វ មួយសន្ទុះក្រោយមកគាត់ក៏បានមកដល់។ គាត់បាននិយាយថា មេគោនោះបានលេបខ្សែចូលទៅក្នុងពោះ ដូច្នេះវាមិនអាចរស់ផុតពីថ្ងៃនេះឡើយ។

ខ្ញុំបានកត់លេខទូរស័ព្ទរបស់ក្រុមហ៊ុនដែលធ្វើផលិតផលចេញពីសាច់សត្វ ដើម្បីឱ្យភរិយារបស់ខ្ញុំអាចទូរស័ព្ទហៅពួកគេឱ្យមកយកមេគោនេះ រំពេចណាវាស្លាប់នោះ។

ពីមុនខ្ញុំបានចាកចេញ យើងបានធ្វើការអធិស្ឋានជាគ្រួសារ។ កូនប្រុសពៅរបស់យើងបានធ្វើការអធិស្ឋាន។ បន្ទាប់ពីគាត់បានទូលសុំព្រះវរបិតាឱ្យ "ប្រទានពរដល់ឪពុករបស់ខ្លួនដែលរៀបនឹងធ្វើដំណើរ និងប្រទានពរដល់យើងទាំងអស់គ្នា" រួចហើយគាត់ក៏បានចាប់ផ្តើមធ្វើការទូលអង្វរដ៏ស្មោះអស់ពីចិត្តមួយ។ គាត់បាននិយាយថា "ព្រះវរបិតាសួគ៌ សូមប្រទានពរដល់មេគោឈ្មោះ បូស៊ី ដើម្បីកុំឱ្យវាជួបនឹងបញ្ហាអ្វីឡើយ"។

ក្នុងសន្និសីទ នៅរដ្ឋ កាលីហ្វ័រញ៉ា ខ្ញុំបានរៀបរាប់ពីហេតុការណ៍នេះ ហើយបាននិយាយថា "កូនប្រុសរបស់ខ្ញុំត្រូវរៀនថា យើងមិនអាចទទួលបានអ្វីគ្រប់យ៉ាងដោយងាយស្រួលដូចដែលយើងអធិស្ឋានឡើយ"។

តែផ្ទុយទៅវិញខ្ញុំបានរៀននូវមេរៀនមួយ ពុំមែនជាកូនប្រុសរបស់ខ្ញុំឡើយ។ នៅពេលខ្ញុំត្រឡប់មកវិញនៅយប់ថ្ងៃអាទិត្យ នោះបូស៊ី "បានធូរស្បើយឡើងវិញ"។

ដំណើរការនេះពុំកើតមានតែចំពោះពួកព្យាការីតែម្យ៉ាងនោះទេ។ អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ គឺកើតមានស្មើភាពគ្នាចំពោះបុរសស្ត្រី រួមទាំងកុមារតូចៗផងដែរ។ គឺនៅក្នុងអំណោយទាន និងអំណាចដ៏អស្ចារ្យនេះហើយ ដែលឱសថព្យាបាលខាងវិញ្ញាណសំរាប់បញ្ហានានាអាចត្រូវបានគេរកឃើញ។

"ហើយឥឡូវនេះ មើលចុះ ទ្រង់រំលែកព្រះបន្ទូលរបស់ទ្រង់ដល់មនុស្សដោយពួកទេវតា មែនហើយ មិនត្រឹមតែដល់ ពួកបុរសទេ តែដល់ពួកស្ត្រីផងដែរ។ ឥឡូវនេះ នេះពុំទាន់អស់នៅឡើយទេ កូនក្មេងតូចៗក៏បានទទួលព្រះបន្ទូល ទាំងឡាយជាច្រើនផងដែរ ដែលមានពេលខ្លះ បានធ្វើឱ្យប្រាជ្ញា និងអ្នកចេះដឹងជ្រប់មុខ" (អាលម៉ា 32:23)។

ព្រះអម្ចាស់មានរបៀបជាច្រើននៅក្នុងការចាក់ចំណេះដឹងចូលទៅក្នុងគំនិតរបស់យើង ដើម្បីបំផុសគំនិត ដឹកនាំ បង្រៀន កែតំរូវ និងព្រមានដល់យើង។ ព្រះអម្ចាស់បានមានបន្ទូលថា "យើងនឹងប្រាប់អ្នកនៅក្នុងគំនិតរបស់អ្នក និងនៅក្នុងចិត្តរបស់អ្នកដោយព្រះវិញ្ញាណបរិសុទ្ធដែលនឹងសណ្ឋិតមកលើអ្នក ហើយដែលនឹងគង់នៅក្នុងចិត្តរបស់អ្នក" (គ. និង ស. 8:2)។

ហើយអេណុសបានកត់ត្រាថា : "នៅពេលខ្ញុំកំពុងសញ្ជឹងគិតក្នុងវិញ្ញាណ មើលចុះ សម្លេងនៃព្រះអម្ចាស់បានចូលមកក្នុងគំនិតរបស់ខ្ញុំទៀត" (អេណុស 1:10)។

អ្នករាល់គ្នាអាចដឹងនូវរឿងទាំងឡាយដែលអ្នកត្រូវដឹង។ សូមអធិស្ឋានថា អ្នករាល់គ្នានឹងរៀនទទួលយកការបំផុសគំនិតនោះ ហើយបន្តមានភាពសក្តិសមដើម្បីទទួលការណ៍នេះ។ សូមរក្សាឧបករណ៍នោះ---ជាគំនិតរបស់អ្នក---ឱ្យបានស្អាតស្អំ និងជៀសឱ្យផុតពីភាពឥតសណ្តាប់ធ្នាប់នៃពិភពលោកនេះ។

មានគ្រាមួយ អែលឌើរ ហ្គ្រាហាំ ដបុលយូ ដក់ស៊ី ដែលបានបំរើនៅក្នុងក្រុមទីពីរនៃពួកចិតសិបនាក់ បានប្រាប់ខ្ញុំពី បទពិសោធន៍មួយ។ អ្នកម្តាយរបស់គាត់ ដែលក្រោយមកបានក្លាយទៅជាទីប្រឹក្សានៅក្នុងគណៈប្រធានអង្គការបឋមសិក្សាទូទៅ ក៏បានប្រាប់ខ្ញុំពីបទពិសោធន៍នេះដែរ។

នៅក្នុងសម័យសង្គ្រាមលោកលើកទីពីរ គាត់គឺជាទ័ពជើងទឹកដែលឈរជើងនៅប្រទេសចិន។ គាត់ ហើយនឹងអ្នកផ្សេងពីរបីនាក់ទៀតបានឡើងជិះរថភ្លើងដើម្បីទៅដើរលេងនៅក្នុងទីក្រុង ទៀនស៊ិន។

ក្រោយមក ពួកគាត់បានឡើងជិះរថភ្លើងត្រឡប់មកមូលដ្ឋានរបស់ខ្លួនវិញ ប៉ុន្តែបន្ទាប់ពីជិះបានជាងមួយម៉ោងមក រថភ្លើងនោះបានរត់សំដៅ ទៅទិសខាងជើង។ ពួកគាត់បានឡើងជិះរថភ្លើងខុស! ពួកគាត់ក៏មិនចេះនិយាយភាសាចិនទៀត។ ពួកគាត់បានទាញខ្សែសង្គ្រោះបន្ទាន់ ដើម្បីសុំឱ្យរថភ្លើងឈប់។ ពួកគាត់ក៏ត្រូវបានដាក់ចុះនៅទីកន្លែងមួយនៅជនបទដាច់ស្រយាល គ្មានអ្វីសោះ ដូច្នេះពួកគាត់ត្រូវដើរត្រឡប់ទៅកាន់ទីក្រុងវិញ។

បន្ទាប់ពីបានដើរអស់មួយស្របក់មក ពួកគាត់បានរកឃើញរទេះស្ទប់តូចមួយប្រភេទ ដែលពួកកម្មករតាមផ្លូវរថភ្លើងប្រើ។ ពួកគាត់បានរៀបចំដាក់វានៅលើផ្លូវរថភ្លើង ហើយបានចាប់ផ្ដើមសប់ខ្យល់ដើម្បីឱ្យរទេះនោះអាចរត់នៅផ្លូវដែក។ ពួកគាត់បានធ្វើដំណើរនៅលើរទេះនោះចុះពីផ្លូវចោត ហើយក៏ត្រូវរុញវាឡើងទៅលើផ្លូវដែលមានទួលខ្ពស់ផងដែរ។

នៅពេលពួកគាត់បានមកដល់ផ្លូវចំណោតមួយ ពួកគាត់បានស្រវេស្រវាឡើងទៅលើរទេះនោះ ហើយចាប់ផ្ដើមរអិលចុះមក។ ប្រ្គាហាំ គឺជាមនុស្សចុងក្រោយគេដែលត្រូវឡើងជិះនៅលើរទេះនោះ។ កន្លែងដែលនៅសល់សំរាប់គាត់ គឺនៅផ្នែកខាងមុខនៃរទេះនោះ។ គាត់បានខំរត់តាមរទេះនោះ ហើយនៅទីបំផុតគាត់ក៏លោតឡើងជិះលើរទេះនោះបាន។ នៅពេលនោះ គាត់ក៏បានរអិលដួលធ្លាក់នៅពីមុខរទេះនោះ។ គាត់បានរមៀលខ្លួនចុះ ហើយយកជើងរបស់គាត់ទប់នឹងរទេះនោះ ដើម្បីការពារកុំឱ្យវាបរកិនពីលើគាត់។ នៅពេលរទេះនោះមានល្បឿនយ៉ាងលឿន នោះគាត់បានឮសម្លេងរបស់អ្នក ម្ដាយបន្លឺឡើងថា "បាត់ កូនត្រូវប្រុងប្រយ័ត្នឱ្យមែនទែន!"

គាត់ពាក់ស្បែកជើងកវែងក្រាស់របស់ទាហាន។ ជើងរបស់គាត់បានភ្លាត់ចូលទៅក្រោមរទេះនោះ ហើយទ្រនាប់ស្បែកជើងដ៏រឹងរបស់គាត់បាននៅជាប់នឹងស្ពឺនៃកង់រទេះនោះ ហើយបានធ្វើឱ្យវាឈប់ប្រមាណជា 30 សង់ទីម៉ែត្រពី ដៃរបស់គាត់។

ឪពុកម្ដាយរបស់គាត់ ដែលកំពុងគ្រប់គ្រងនៅក្នុងបេសកកម្មនៃអតីតរាជធានីរបស់ប្រទេសនីហ្សេរីយ៉ា នាពេលនោះ បានកំពុងសំរាកនៅក្នុងបន្ទប់សណ្ឋាគារមួយ។ អ្នកម្ដាយរបស់គាត់បានក្រោកឡើងប្រមាណជាម៉ោង 2:00 ភ្លឺ ហើយបានដាស់ស្វាមីរបស់គាត់ឱ្យក្រោកឡើង ដោយនិយាយថា : "បាត់ មានរឿងធំហើយ!" ពួកគាត់បានលុតជង្គង់ចុះនៅក្បែរគ្រែ ហើយបានអធិស្ឋានដើម្បីសុំឱ្យកូនប្រុសរបស់ខ្លួនមានសុវត្ថិភាព។

សំបុត្របន្ទាប់មកដែលគាត់ទទួល បានសរសេរថា "បាត់ មានរឿងអី? តើកូនកើតអី?"

បន្ទាប់មកគាត់ក៏បានសរសេរប្រាប់ឪពុកម្ដាយពីរឿងដែលបានកើតឡើង។ នៅពេលពួកគេប្រៀបធៀបពីពេលវេលា ពេលដែលគាត់បានរមៀលខ្លួននៅលើផ្លូវរទេះភ្លើងនោះ គឺជាពេលដែលឪពុកម្ដាយគាត់បានលុតជង្គង់នៅក្នុងបន្ទប់សណ្ឋាគារទូលសុំឱ្យគាត់មានសុវត្ថិភាពក្នុងពេលនៅឆ្ងាយពីគ្នានោះ។

បទពិសោធន៍នៃការបំផុសគំនិត និងការអធិស្ឋានទាំងនេះ ពុំមែនជារឿងចម្លែកនៅក្នុងសាសនាចក្រនោះឡើយ។ ការណ៍ទាំងនេះគឺជាផ្នែកមួយនៃវិវរណៈ ដែលព្រះវរបិតាសួគ៌យើងបានប្រទានដល់យើង។

ឧបករណ៍មួយដ៏មុតស្រួចបំផុតរបស់មាសត្រូវ គឺជាការធ្វើឱ្យយើងជឿថា យើងលែងមានភាពសក្តិសមដើម្បីធ្វើការអធិស្ឋានទៀតហើយ។ មិនថាអ្នករាល់គ្នាជាមនុស្សប្រភេទណា ឬអ្នករាល់គ្នាបានធ្វើអ្វីខ្លះនោះទេ អ្នកនៅតែមានលទ្ធភាពធ្វើការអធិស្ឋានជានិច្ច។

ព្យាការី យ៉ូសែប ស្ម៊ីធ បានសន្យាថា "មនុស្សទាំងឡាយណាដែលមានរូបកាយ គឺមានអំណាចលើពួកដែលគ្មានរូបកាយ"។9

នៅពេលកើតមានការល្បួង នោះអ្នករាល់គ្នាអាចបង្កើតរបៀបមួយដើម្បីលុបបំបាត់វាចេញពីគំនិតរបស់អ្នក ប្រហែលជាការនឹកចាំពី ពាក្យនៅក្នុងទំនុកដំកើងដែលអ្នកពេញចិត្ត។ គំនិតរបស់អ្នក គឺអ្នកជាអ្នកបញ្ជា។ រូបកាយរបស់អ្នក គឺជាឧបករណ៍នៃគំនិតរបស់អ្នក។ នៅពេលគំនិតមិនសក្តិសមមួយចំនួនបានជ្រាតចូលទៅក្នុងគំនិតរបស់អ្នក សូមជំនួសគំនិតនោះ ដោយការលុបបំបាត់វាចោល។ តន្ត្រីសមរម្យ គឺមានឥទ្ធិពលណាស់ ហើយវាអាចជួយអ្នករាល់គ្នាឱ្យគ្រប់គ្រង លើគំនិតរបស់អ្នកបាន។ 10

នៅពេល អូលីវើរ ខៅឌើរី បានបរាជ័យនៅក្នុងការចង់បកប្រែ នោះព្រះអម្ចាស់បានមានបន្ទូលប្រាប់គាត់ថា ៖

"មើលចុះ អ្នកពុំយល់ឡើយ អ្នកបានសន្និដ្ឋានថា យើងនឹងប្រទានឯកសិទ្ធិនេះដល់អ្នក កាលអ្នកពុំបានយកមកគិតសោះ ក្រៅពីសុំពីយើង។

"ប៉ុន្តែ មើលចុះ យើងប្រាប់អ្នកថា អ្នកត្រូវសិក្សាក្នុងគំនិតរបស់អ្នក រួចហើយអ្នកត្រូវសូមដល់យើង បើសិនជាការណ៍ នោះត្រឹមត្រូវ ហើយបើសិនជាត្រឹមត្រូវ នោះយើងនឹងបណ្ដាលឱ្យទ្រូងរបស់អ្នកខ្លួលខ្មាញ់ខាងក្នុង ហេតុដូច្នោះហើយ អ្នកនឹងមានអារម្មណ៍ថា ការណ៍នោះត្រឹមត្រូវ។

"ប៉ុន្តែបើសិនជាការណ៍នោះមិនត្រឹមត្រូវវិញ នោះអ្នកនឹងពុំមានអារម្មណ៍យ៉ាងដូច្នោះឡើយ" (គ. និង ស. 9:7--9)។

គោលការណ៍នោះ ត្រូវបានបង្ហាញតាមរយៈដំណើររឿងរបស់ក្មេងស្រីម្នាក់។ នាងមានការតូចចិត្តនឹងបងប្រុសរបស់នាង ដែលបានរៀបចំអន្ទាក់មួយដើម្បីចាប់សត្វចាប។

ដោយមិនអាចរកមនុស្សឱ្យជួយបាន នោះនាងបាននិយាយប្រាប់ខ្លួនឯងថា "មែនហើយ ខ្ញុំនឹងធ្វើការអធិស្ឋាន ដើម្បីដោះស្រាយបញ្ហានេះ"។

បន្ទាប់ពីការអធិស្ឋាន នោះក្មេងស្រីតូចម្នាក់នេះបានប្រាប់ទៅម្ដាយរបស់ខ្លួនថា "កូនដឹងថា អន្ទាក់នេះនឹងមិនអាចចាប់ សត្វចាបណាមួយបានឡើយ ពីព្រោះកូនបានអធិស្ឋានឱ្យកើតឡើងដូច្នេះ។ កូន *ជឿជាក់* ថាវាមិនអាចចាប់បានសត្វចាប ណាមួយឡើយ!"

ម្ដាយរបស់នាងបាននិយាយថា "តើកូនមានទំនុកចិត្តបែបនេះបានដោយរបៀបណា?"

នាងបានឆ្លើយថា "បន្ទាប់ពីកូនបានអធិស្ឋានពីបញ្ហានេះរួចមក នោះកូនបានចេញទៅ ហើយក៏បានទាត់អន្ទាក់ដ៏កញ្ចាស់នោះឱ្យបាក់បែកអស់ហើយ!"

សូមអធិស្ឋាន ទោះជាអ្នករាល់គ្នានៅក្មេង ហើយមានចិត្តមោះមុតដូចជាព្យាការី អាលម៉ា ឬមានគំនិតល្អិតល្អន់ដូចជា អាម៉ូលេកដែល "បានដឹងអំពីការណ៍ទាំងនេះ តែ...ធ្វើជាមិនដឹង"ក្ដី (អាលម៉ា 10:6)។

សូមរៀនអធិស្ឋាន។ សូមអធិស្ឋានឱ្យបានញឹកញាប់។ សូមអធិស្ឋាននៅក្នុងគំនិត និងដួងចិត្តរបស់អ្នក។ សូមលុតជង្គង់ចុះអធិស្ឋាន។ ការអធិស្ឋាន គឺជាកូនសោផ្ទាល់ខ្លួនរបស់អ្នកដើម្បីទៅកាន់ស្ថានសួគ៌។ មេសោ គឺស្ថិតនៅចំពោះមុខរបស់អ្នក។ ហើយបានរៀនដើម្បីបញ្ចប់រាល់ការអធិស្ឋានរបស់ខ្ញុំជាមួយនឹងឃ្លា "សូមឱ្យព្រះហឫទ័យរបស់ទ្រង់បានសំរេច" (ម៉ាថាយ 6:10 សូមមើល លូកា 11:2 នីហ្វៃទី 3 13:10 ផងដែរ)។

សូមកុំរំពឹងទុកចង់ឱ្យរួចផុតពីឧបសគ្គ ការខកចិត្ត ការឈឺចាប់ និងការបាក់ទឹកចិត្តទាំងស្រុងនោះឡើយ ត្បិតរឿងទាំងនេះ គឺជារឿងដែលយើងត្រូវបានបញ្ជូនឱ្យមកស៊ូទ្រាំ។

មានកវីម្នាក់បានសរសេរថា :

យើងបានធ្វើឱ្យផែនការ
ដែលព្រះអម្ចាស់បានបង្កើតឡើងមានភាពស្មុគស្មាញ
ដោយសារតែដៃខ្វះការគិតគូរ និងខ្វះការអត់ធ្មត់។
ហើយនៅពេលយើងស្រែកយំទាំងឈឺចាប់ នោះទ្រង់មានបន្ទូលថា
"កុំរអ៊ូច្រើនពេក ព្រោះយើងកំពុងដោះស្រាយបញ្ហាដែលឯងបានចងនោះឯង"។ 11

ព្រះគម្ពីរបានសន្យាថា : "ត្បិតគ្មានសេចក្ដីល្បួងណាកើតដល់អ្នករាល់គ្នា ក្រៅពីសេចក្ដីល្បួងដែលត្រូវខាងមនុស្សលោកទេ រីឯទ្រង់ក៏ស្មោះត្រង់ដែរ ទ្រង់មិនឱ្យកើតមានសេចក្ដីល្បួងហួសកំលាំងរបស់អ្នករាល់គ្នាឡើយ គឺនៅវេលាណាដែលត្រូវល្បួង នោះទ្រង់ក៏រៀបផ្លូវឱ្យជៀសរួច ដើម្បីឱ្យអ្នករាល់គ្នាអាចនឹងទ្រាំបាន" (កូរិនថូសទី 1 10:13)។

ព្រះអង្គសង្គ្រោះមានបន្ទូលថា "ចូរចូលមកជិតយើង នោះយើងនឹងចូលទៅជិតអ្នក ចូរព្យាយាមស្វែងរកយើងនោះ អ្នករាល់គ្នានឹងបានជួបយើង ចូរសូមនោះអ្នករាល់គ្នានឹងបានទទួល ចូរគោះ នោះតែងនឹងបានបើកឱ្យអ្នក" (គ. និង ស. 88:63)។

យើងបានចាប់ផ្ដើមសម័យប្រជុំនៃសន្និសីទនេះ ដោយមានការគាំទ្រដល់ពួកអ្នកមានសិទ្ធិអំណាចទូទៅ។ ជាដំបូងយើងបានគាំទ្រប្រធាន ថូម៉ាស អេស ម៉នសុន ជាប្រធាននៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ។ ខ្ញុំស្គាល់ប្រធាន ម៉នសុន ហើយខ្ញុំគិតថា មានមនុស្សជាច្រើននៅលើផែនដីនេះក៏ស្គាល់លោកផងដែរ ហើយខ្ញុំចង់ថ្លែងជាសាក្សីដ៏ពិសេសមួយថា លោកត្រូវបាន "ហៅពីព្រះដោយការព្យាករណ៍" (មាត្រានៃសេចក្ដីជំនឿ 1:5)។ លោកត្រូវការការអធិស្ឋានរបស់យើង---ហើយភរិយារបស់លោក អ្នកស្រី ហ្វ្រេនស៊ីស និងគ្រួសាររបស់លោក---មានទូវបន្ទុកដ៏ធំមកលើលោក។

ខ្ញុំសូមអធិស្ឋានថា លោកនឹងត្រូវបានគាំទ្រទាំងផ្នែករូបកាយ គំនិត និងវិញ្ញាណ ហើយសូមឱ្យការណ៍នេះនឹងបញ្ជាក់យ៉ាងច្បាស់ដល់សាសនាចក្រនេះ ក៏ដូចជាពួកអ្នកដែលជិតស្និទ្ធនឹងលោកផងដែរថា លោកត្រូវបាន "ហៅពីព្រះដោយការព្យាករណ៍"។ រួចហើយ

"ដោយការដាក់ដៃលើ ដោយអស់អ្នកណាដែលមានសិទ្ធិអំណាច ដើម្បីនឹងផ្សាយដំណឹងល្អ ហើយប្រព្រឹត្តពិធីការទាំងឡាយនៃដំណឹងល្អ" (មាត្រានៃសេចក្ដីជំនឿ 1:5) លោកត្រូវបានរៀបចំឡើងនៅក្នុងមុខតំណែងរបស់លោក ។

សូមឱ្យព្រះអម្ចាស់ប្រទានពរដល់យើង និងគាំទ្រដល់ប្រធានម៉នសុន និងគ្រួសាររបស់លោកនៅគ្រប់កិច្ចការទាំងអស់ ដែលចាំបាច់ដើម្បីអនុវត្តកិច្ចការដ៏ធំដែលបានផ្ទុកនៅលើស្មារបស់លោក ។ ខ្ញុំសូមថ្លែងជាសាក្សីពីកិច្ចការនោះ ហើយបួងសួងសំរាប់ពរជ័យនោះក្នុងនាមជាអ្នកបំរើម្នាក់របស់ព្រះអម្ចាស់ និងនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. សូមមើល គ. និង ស. 84:46 ។

2. សូមមើល គ. និង ស 138:56 សូមមើល រ៉ូម 8:16 ផងដែរ ។

3. សូមមើល គ. និង ស. 101:78 ។

4. សូមមើល កូរិនថូសទី 1 2:14 គ. និង ស. 8:2; 9:8—9 ។

5. សូមមើល គ. និង ស. 11:13; 100:5 ។

6. សូមមើល នីហ្វៃទី 1 17:45 ។

7. សូមមើល វិលហ្វូឌ វូឌរុហ្វ នៅក្នុង *Conference Report* ថ្ងៃទី 7 ខែ មេសា ឆ្នាំ 1898 ទំព័រ 30 "Remarks" *Deseret Weekly* ថ្ងៃទី 5 ខែ កញ្ញា ឆ្នាំ 1891 ទំព័រ 323 ។

8. សូមមើល វិលហ្វូឌ វូឌរុហ្វ *Leaves from My Journal* (ឆ្នាំ 1881) ទំព័រ 88 ។

9. *Teachings of Presidents of the Church: Joseph Smith* (ឆ្នាំ 2007) ទំព័រ 211 ។

10. សូមមើល គ. និង ស. 25:12 ។

11. អ្នកនិពន្ធមិនស្គាល់ឈ្មោះ នៅក្នុង Jack M. Lyon and others រៀបរៀងដោយ *Best-Loved Poems of the LDS People* (ឆ្នាំ 1996) ទំព័រ 304 ។